s

# មេរោគកូរ៉ូណាប្រភេទថ្មី (COVID-19)

## នាយកដ្ឋានសុខភាពសាធារណៈរបស់ខោនធី Los Angeles
## ការណែនាំសម្រាប់ការប្រមូលផ្តុំឯកជនទ្រង់ទ្រាយតូច

**កំណត់សម្គាល់៖** មន្ត្រីសុខាភិបាលខោនធី Los Angeles បានចេញសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលឲ្យនៅផ្ទះមានសុវត្ថិភាពជាងដែលមានគោលដៅបណ្តោះអាសន្នដោយសារការកើនឡើងនៅតែបន្ត និងជ័គួរឲ្យកត់សម្គាល់នៃចំនួនករណី ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់បាត់បង់ជីវិតដោយសារជំងឺ COVID-19។

មិនអនុញ្ញាតឲ្យមានការប្រមូលផ្តុំ និងព្រឹត្តិការណ៍សាធារណៈ និងឯកជនទាំងអស់ដែលមានមនុស្សមកពីគ្រួសារច្រើនជាងមួយគ្រួសារឡើយ លើកលែងសម្រាប់សេវាកម្មផ្អែកលើជំនឿ និងការបញ្ចេញមតិនយោបាយខាងក្រៅអគារ និងដូចមានថ្លែងនៅក្នុងកឋាខណ្ឌទី 9 នៃសេចក្តីបង្គាប់បណ្តោះអាសន្នដែលបានកែសម្រួលនេះ។ ការប្រមូលផ្តុំដែលបានអនុញ្ញាត ត្រូវតែអនុលោមតាមសេចក្តីតម្រូវសម្រាប់ការប្រើប្រាស់របាំងមុខ និងការរក្សាគំលាតរាងកាយ និងសម្រាប់ការកាត់បន្ថយចំនួនមនុស្សដែលចាំបាច់ដើម្បីអនុញ្ញាតឲ្យមានគំលាតប្រាំមួយហ្វីតរវាងក្រុមគ្រួសារ។

សម្រាប់ព័ត៌មានបន្ថែម សូមមើល សេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលឲ្យនៅផ្ទះមានសុវត្ថិភាពជាងដែលមានគោលដៅបណ្តោះអាសន្ន ដែលត្រូវបានចុះផ្សាយនៅលើគេហទំព័រនេះ ph.lacounty.gov/media/Coronavirus/reopening-la.htm#orders